ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

អភាទីផ្នែកព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ០៩

ចុះថ្ងៃទី ១.០៤.៩៤

សាលដីកា

លេខ: ៤៩

ចុះថ្ងៃទី៣.៧.៩៤

តាងនាមប្រជារាស្ត្រខ្មែរ

តុ លា កា រ កំ ពូ ល

ក្នុងបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៧ ខែ មីនា ឆ្នាំ ១៩៩៤ ដោយមានសមាសភាពដូចតទៅ :

១ - ឯកឧត្តម ឌិត មុន្នី ប្រធាន

២ - លោក ឈឹម ស៊ីផល ចៅក្រម

៣ - លោក សោម សិរីវឌ្ឍ ចៅក្រម

៤ - លោក ប្រាក់ គឹមសាន ចៅក្រម

៥ - លោក យស់ ល្អខឿន ចៅក្រមរបាយការណ៍

ក្រឡាបញ្ជី លោក ប៊ុល វណ្ណា

តំណាងមហាអយ្យការ លោក ឈាយ សារី ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ ២០៩ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៣ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ០៩ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ១៩៩៤ របស់តុលាការកំពូល ។

ពីបទ : ប្លន់ទ្រព្យសម្បត្តិប្រដាប់ដៃ ប្រព្រឹត្តកាលពីថ្ងៃទី០១ - ០៣ - ៩៣ នៅសង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ បទល្មើសដែលមានចែងនាមបញ្ញត្តិមាត្រា៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ - ៩ - ៩២ ។

១ - ជនជាប់ចោទឈ្មោះ សោម កុសលីកា "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រី អាយុ ៤៥ ឆ្នាំជាតិខ្មែរ កើតនៅឃុំតាម៉ឺន ស្រុក-ខេត្តបាត់ដំបង មុខរបរ បុគ្គលិកក្រុមហ៊ុនអគ្គិសនីកម្ពុជា ទីលំនៅបច្ចុប្បន្នផ្ទះលេខ៥៣អឺ០ ក្រុម២៤ ផ្លូវលេខ ១៨២ សង្កាត់អូរឬស្សី-មួយ ខណ្ឌ៧មករា ក្រុងភ្នំពេញ ឪពុកឈ្មោះ គឹម ផុន "ស្លាប់" ម្តាយឈ្មោះ ប្រុក ជុកទឹម "រស់" មេម៉ាយ មានកូន០៦នាក់ ទោសពីមុនគ្មាន នៅក្រៅឃុំ ។

មេធាវីលោក ជា ពារា

២ - ជនជាប់ចោទឈ្មោះ នួន សារិន ភេទប្រុស អាយុ៤៤ឆ្នាំជាតិខ្មែរ កើតនៅភូមិ -

អរិយក្សត្រ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល ខុនរបស់ កងខេមរភូមិន្ទ ទីលំនៅសព្វថ្ងៃ ភូមិអរិយក្សត្រ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល ប្រពន្ធឈ្មោះ ស៊ែម សេង មានកូន ០៦ នាក់ ទោសពីមុនគ្មាន នៅក្រៅឃុំ ។

មេធាវី ឬ អ្នកការពារ គ្មាន

- ជនរងគ្រោះឈ្មោះ ដាន វណ្ណា "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រីអាយុ៤០ឆ្នាំ ជាតិខ្មែរ របររកស៊ី នៅផ្ទះ ទីលំនៅសព្វថ្ងៃផ្ទះសង់ថ្មី ផ្លូវលេខ ២៨០ ក្រុម៣៥ សង្កាត់អូឡាំពិក ខណ្ឌចំការមន ក្រុងភ្នំពេញ ។

មេធាវី ឬ អ្នកការពារ គ្មាន

- តាមបណ្តឹងសាទុក្ខលេខ ៥៣៧ ចុះថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ របស់ឈ្មោះ - សោម កុសធីតា ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ២៨០ ចុះថ្ងៃទី១០ ខែ តុលា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី១ នៃសេចក្តីសំរេច ។

- តាមបណ្តឹងសាទុក្ខលេខ ៥៩៦ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ ១៩៩៧ របស់ឈ្មោះ ដាន វណ្ណា ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ២៨០ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញ នាពេលសវនាការថា : ឆ្លងកាត់សវនាការនេះ ដោយផ្អែកលើចំណុចមួយចំនួនអាចកត់សំគាល់បានថា រូបភាពដែលទារប្រាក់ជំពាក់ ដែលកើតឡើងនៅថ្ងៃទី០១ - ៣ - ៩៣ ជារូបភាពប្លន់ ក្នុងករណីនេះជនរងគ្រោះជាកូនបំណុល ។ ការប្តូរទ្រព្យសម្បត្តិមានការប្រគល់ពីបន្ទាយស្លឹក ទៅព្រែកឯង មកអូឡាំពិក ហើយសំដីរបស់ជនជាប់ចោទឆ្លើយមិនពិតទេ ខ្លួនបានពឹងពាក់ទាហានដើម្បីធ្វើសកម្មភាពប្លន់លុយរបស់គេដែលមាននៅក្នុងកាបូប ។ បទល្មើសកើតឡើងនៅថ្ងៃទី០១ - ៣ - ៩៣ គួរតែជនជាប់ចោទដឹងអំពីច្បាប់ ទៀងដំណាក់សុំមិនអាចកោះខ្លួនដើរតួជាតុលាការទៅកន្ទុំក្តីរាស្ត្រ ទោះជាស្វាគីខ្ទាងដោយខ្លួនឯងបានទេ ហើយអំពើកិច្ចសន្យាមិនទាក់ទងក្នុងរឿងប្លន់ដែលត្រូវជំនុំជំរះនៅព្រឹកនេះបានដែរ ។ តាងនាមតំណាងអយ្យការ ស្នើតម្កល់ការចោទប្រកាន់ ដែលក្នុងនោះមានឈ្មោះ សោម កុសធីតា និង នួន ណារិន ។ និងទាហានពីរនាក់ទៀតគ្មានសវតាជាតិ គប្បីបង្គាប់បណ្តឹងអាជ្ញា ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៥២៩ ចុះថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១ - ផ្តន្ទាទោសដាក់ពន្ធនាគារឈ្មោះ នួន ណារិន ភេទប្រុស អាយុ៥៣ឆ្នាំ អតីតយោធាវរៈ ២ - ៥៦ ថ្នាក់វរៈសេនីយត្រី ទីលំនៅ នៅភូមិអរិយក្សត្រ ឃុំអរិយក្សត្រ ស្រុកល្វាឯម ខេត្តកណ្តាល ចំនួន៣ឆ្នាំគិតពីថ្ងៃចាប់ខ្លួនបាន តាមមាត្រា៣៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ពីបទប្លន់ទ្រព្យ - សម្បត្តិ ប្រជាជនកាលពីថ្ងៃទី ០១ - ៣ - ៩៣ នៅទីក្រុងភ្នំពេញ ។

២ - ផ្តន្ទាទោសដាក់ពន្ធនាគារឈ្មោះ សោម កុសធីតា ចំនួន៣ឆ្នាំគត់ដោយគិតពី

ថ្ងៃសាលក្រមចូលជាស្ថាពរ តាមមាត្រាទី៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ពីបទប្លន់ទ្រព្យសម្បត្តិប្រជាជនកាលពីថ្ងៃទី ០១ - ៣ - ៩៣ នៅទីក្រុងភ្នំពេញ ។

៣ - បង្គាប់អោយឈ្មោះ សោម កុលធីតា ប្រគល់ប្រាក់ដុល្លាចំនួន៩.៦៥០ដុល្លាអាមេរិក មាសពេញចំនួន៦ដំឡឹង១ជី៥ហ៊ុន និងជម្ងឺចិត្តចំនួន មួយពាន់ដុល្លាអាមេរិក អោយទៅផាន វណ្ណា វិញ ចាប់ពីថ្ងៃនេះតទៅ ។

៤ - សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ សោម - កុលធីតា និងកំបាំងមុខជនជាប់ចោទឈ្មោះ នួន ណារិន សំរេចបើកផ្លូវឧទ្ធរណ៍រយៈពេល ២ខែគិតពីថ្ងៃប្រកាសសាលក្រមតទៅ ។

- បានឃើញបណ្តឹងទាស់ចុះថ្ងៃទី១០ - ០២ - ១៩៩៥ របស់ឈ្មោះ នួន ណារិន ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ ៤២៩ ចុះថ្ងៃទី ០៤ - ១១ - ៩៤ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចទី១ នៃសេចក្តីសំរេច ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញ បានសន្និដ្ឋាននាសវនាការលើកទី២ថា នេះជាលើកទី២ហើយដែលឈ្មោះ នួន ណារិន ពុំព្រមចូលខ្លួនទៅចំពោះមុខតុលាការ ហើយក្នុងរឿងនេះតុលាការបានសំរេចផ្តន្ទាទោសឈ្មោះ សោម កុលធីតា ចំនួន៣ឆ្នាំ ហើយកំបាំងមុខ នួន ណារិន ដោយដាក់គុកចំនួន៣ឆ្នាំម្តងរួចមកហើយ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់នៅចំពោះមុខតុលាការអស់ហើយថា ឈ្មោះ នួន ណារិន និងបក្សពួកពិតជាបានប្លន់ទ្រព្យសម្បត្តិ របស់ខ្លួនពិតប្រាកដមែន ។

ការអន្តរាយពិតជាមានហើយ បើគ្មានឈ្មោះ នួន ណារិនទៅធ្វើអន្តរាគមន៍ទេ ក៏គ្មានអំពើកើតឡើងដែរ ។ ក្នុងនាមជាតំណាងអយ្យការសូមតម្កល់ការចោទប្រកាន់ដដែល ដោយស្នើតុលាការផ្តន្ទាទោសជនជាប់ចោទតាមមាត្រាទី ៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ជូនរឿងទៅតុលាការសំរេចតាមច្បាប់ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៦៨ " ក " ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ១៩៩៥ របស់តុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១ - តម្កល់សាលក្រមលេខ ៤២៩ ចុះថ្ងៃទី០៤ ខែ១១ ឆ្នាំ ១៩៩៤ ទុកជាបានការពេញទាំងមូល ។

២ - សាលក្រមនេះប្រកាសជាសាធារណៈ កំបាំងមុខនួន ណារិន ជាលើកទី២ ទុកដូចជាចំពោះមុខ សំរេចបើកផ្លូវឧទ្ធរណ៍រយៈពេល២ខែគិតចាប់ពីថ្ងៃប្រកាសសាលក្រមតទៅ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៩១ ចុះថ្ងៃទី០២ ខែ សីហា ឆ្នាំ ១៩៩៥ របស់ឈ្មោះ ផាន វណ្ណា ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ៦៨ " ក " ចុះថ្ងៃទី០៥ - ០៦ - ៩៥ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចទី៣ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ៧៣ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៥ របស់លោក -

លោក សរចេង វិញ្ញូសក្តិ " អ្នកការពារអោយឈ្មោះ នួន ណារិន " ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌ លេខ ៦៨ " ក " ចុះថ្ងៃទី ០៥ - ០៦ - ៨៥ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ បានសន្និដ្ឋាន ថា សាលក្រមលេខ ៤២៨ ចុះថ្ងៃទី ០៤ - ១១ - ៨៤ របស់តុលាការក្រុងភ្នំពេញជាសាលក្រមកំបាំងមុខ ជនល្មើស នួន ណារិន ហើយឈ្មោះនេះបានទទួលដំណឹងនៅថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ១៩៨៥ និងបានប្តឹងទាស់ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨៥ ដែលជាបណ្តឹងទាស់ធ្វើនៅកំណត់ត្រឹមត្រូវនៃបណ្តឹងទាស់ ។

ដូច្នេះ ដោយគ្មានសេចក្តីបញ្ជាក់ច្បាស់លាស់ថា ខ្លួនបោះបង់សិទ្ធិប្តឹងទាស់ ហើយសុំចាត់ទុក បណ្តឹងតវ៉ារបស់ខ្លួនជាបណ្តឹងឧទ្ធរណ៍ទេ សាលាឧទ្ធរណ៍មិនមានសមត្ថកិច្ចជំនុំជំរះលើបណ្តឹងនេះបានឡើយ ។

អាស្រ័យហេតុនេះមហាអយ្យការសំរេចមិនទាន់ចុះបញ្ជីជំនុំជំរះដើម្បីសាលាឧទ្ធរណ៍ ជំនុំជំរះលើបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទ សោម កុសុធីតា និងលើបណ្តឹងឧទ្ធរណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដាន វិណ្ណា ដោយត្រូវរង់ចាំតុលាការក្រុងភ្នំពេញសំរេចសេចក្តីលើបណ្តឹងទាស់របស់ជនល្មើស នួន ណារិន សិន ។

- បានឃើញលិខិតលេខ ៣៨៣ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៨៥ របស់អគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ ផ្ញើជូនព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ ដោយជូនភ្ជាប់មកជាមួយសំណុំរឿង ឧក្រិដ្ឋលេខ ៨៤ ចុះថ្ងៃទី ១២ - ០១ - ៨៤ ។

- បានឃើញសេចក្តីសំរេចរបស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញដែលបាន សំរេច :

១ - ចោទប្រកាន់លើឈ្មោះ សោម កុសុធីតា និង នួន ណារិន ពីបទប្លន់ទ្រព្យ-សម្បត្តិអ្នកដទៃកាលពីថ្ងៃទី០១ - ៣ - ៨៣ តាមមាត្រាទី៣៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២ - បង្អង់បណ្តឹងអាជ្ញាលើសាហាចារីទាក់ទិនចំនួន៣នាក់ ព្រោះគ្មានសារតាងជាក់ត្រឹមត្រូវ ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៦០ " ក " ចុះថ្ងៃទី ២៩ - ៤ - ៨៦ របស់ តុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១ - បដិសេធសាលក្រមព្រហ្មទណ្ឌលេខ៤២៨ ចុះថ្ងៃទី០៤ - ១១ - ៨៤ និងសាលក្រម លេខ ៦៨ " ក " ចុះថ្ងៃទី០៥ - ៦ - ៨៥ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

២ - ផ្តន្ទាទោសដាក់ពន្ធនាគារឈ្មោះ សោម កុសុធីតា ភេទស្រី អាយុ ៤៥ឆ្នាំ ជាតិខ្មែរកំណត់៣ឆ្នាំ " បីឆ្នាំ " តែទោសនេះព្យួរទាំងអស់ដោយទុករយៈពេលសាកល្បង ៥ ឆ្នាំដោយគិត ពីថ្ងៃប្រកាសសាលក្រមនេះតទៅ តាមមាត្រាទី ៣៤ និងមាត្រា៣០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ពី បទប្លន់ទ្រព្យសម្បត្តិពលរដ្ឋ ប្រព្រឹត្តនៅក្រុងភ្នំពេញកាលពីថ្ងៃទី ០១ - ៣ - ៨៣ ។

៣ - បង្គាប់អោយឈ្មោះ សោម កុសុធីតា សងប្រាក់ចំនួន ៥.៦៥០ដុល្លាអាមេរិក " ប្រាំពាន់ប្រាំមួយរយហាសិប " មាសដេញចំនួន៦ជីឡើងមួយជីប្រាំហ៊ុន និងប្រាក់ជំងឺចិត្តចំនួន ១.០០០ដុល្លា-អាមេរិកអោយទៅឈ្មោះ ដាន វិណ្ណា វិញ ។ ក្នុងករណីរឹងទទឹងមិនព្រមសងសំរេចដាក់គុកបង្ខំលើ-

រូបកាយទណ្ឌិតចំនួន ២ ឆ្នាំតាមមាត្រាទី៧នៃច្បាប់ស្តីពីវិធីដាក់គុកបង្ខំរូបកាយក្នុងរឿងព្រហ្មទណ្ឌ។

៤ - សំរេចអោយឈ្មោះ នួន ណារិន ភេទប្រុស អាយុ ៤៣ឆ្នាំជាតិខ្មែរ រួចខ្លួនពីការចោទប្រកាន់ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៥ - សាលក្រមនេះជំនុំជំរះជាសាធារណៈ ចំពោះមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី សំរេចបើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៧៥ ចុះថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ១៩៩៦ របស់ឈ្មោះ សោម កុលធីតា ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ ៦០ " ក " ចុះថ្ងៃទី២៨ - ៤ - ៩៦ របស់តុលាការក្រុងភ្នំពេញ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៧៧ ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ១៩៩៦ របស់ឈ្មោះ ផាន វណ្ណា ដែលប្តឹងតវ៉ាពីសាលក្រមព្រហ្មទណ្ឌលេខ ៦០ " ក " ចុះថ្ងៃទី ២៨ - ៤ - ៩៦ របស់តុលាការក្រុងភ្នំពេញ ត្រង់ចំណុចទី៣ និងទី៤ នៃសេចក្តីសំរេចសាលក្រម ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា :

១ - ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ សោម កុលធីតា ចុះថ្ងៃទី ២៥ - ៦ - ៩៦ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាល់នឹងគតិច្បាប់ ។

២ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៧ - ៦ - ៩៦ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ - ផាន វណ្ណា ទុកជាត្រឹមត្រូវតាមទំរង់និងគតិច្បាប់ ។

៣ - បដិសេធសាលក្រមលេខ ៦០ " ក " ចុះថ្ងៃទី ២៨ - ៤ - ៩៦ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។ សំរេចតម្កល់សាលក្រមលេខ ៦៨ " ក " ចុះថ្ងៃទី ០៥ - ៦ - ៩៥ របស់តុលាការក្រុងទុកជាបានការតទៅ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ២០៨ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ដែលបានសំរេច :

១ - ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៥ - ៦ - ៩៦ និងចុះថ្ងៃទី ២៥ - ១១ - ៩៤ របស់ សោម កុលធីតា , បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៤ - ៧ - ៩៥ របស់ នួន ណារិន និងបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី - ០២ - ៨ - ៩៥ របស់ ផាន វណ្ណា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២ - បដិសេធសាលក្រមលេខ ៦០ " ក " ចុះថ្ងៃទី ២៨ - ៤ - ៩៦ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៣ - បដិសេធសាលក្រមលេខ ៦៨ " ក " ចុះថ្ងៃទី ០៥ - ៦ - ៩៥ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៤ - ផ្តន្ទាទោសឈ្មោះ សោម កុលធីតា ភេទស្រី អាយុ ៤៥ ឆ្នាំដាក់ពន្ធនាគារចំនួន០១ឆ្នាំ តែទោសនេះត្រូវព្យួរដោយមានរយៈពេលសាកល្បង៥ឆ្នាំគិតពីថ្ងៃសាលដីកានេះចូលជាស្ថាពរ ពីបទប្លន់ប្រព្រឹត្តនៅទីក្រុងភ្នំពេញកាលពីថ្ងៃទី០១ - ៣ - ៩៣ តាមមាត្រា៣៤ , ៦៨ , ៧០ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៥ - អោយឈ្មោះ នួន ណារិន ភេទប្រុស អាយុ ៤៣ ឆ្នាំរួចខ្លួនពីបទចោទ ។

៦ - បង្គាប់អោយឈ្មោះ សោម កុលធីតា សងប្រាក់ចំនួន ៥.៦៥០ដុល្លារអាមេរិក ទៅអោយដាន វណ្ណា វិញ ។ ក្នុងករណីមិនព្រមសងសំរេចដាក់គុកបង្ខំដល់រូបកាយចំនួន ២ ឆ្នាំ តាមមាត្រា៧ ច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៧ - សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខសោម កុលធីតា ដាន វណ្ណា កំបាំងមុខ នួន ណារិន បើកផ្លូវប្តឹងទាស់និងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ ៤៣៧ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៧ របស់ឈ្មោះ សោម កុលធីតា ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ២០៨ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ ១៩៩៧ ត្រង់ចំណុចទី៦ នៃសេចក្តីសំរេច ។

- បានឃើញបណ្តឹងសាទុក្ខលេខ ៤៩៦ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ ១៩៩៧ របស់ឈ្មោះ - ដាន វណ្ណា ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ២០៨ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៧ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ១៩៩៨ របស់ឈ្មោះ សោម កុលធីតា ជាម្ចាស់បណ្តឹងសាទុក្ខ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ។

- បានឃើញសារណាចុះថ្ងៃទី ៥ ខែ មីនា ឆ្នាំ ១៩៩៨ របស់ឈ្មោះដាន វណ្ណា ជាម្ចាស់បណ្តឹងសាទុក្ខ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា :

១ - បណ្តឹងសាទុក្ខរបស់នាង សោម កុលធីតា និងនាងដាន វណ្ណា ស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះមកពិនិត្យពិចារណា ។

២ - ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ២០៨ ចុះថ្ងៃទី១០ - ១០ - ៩៨ របស់សាលាឧទ្ធរណ៍ ។

- បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះសោម កុលធីតា នៅពេលជំនុំជំរះថា ប្តីរបស់ឈ្មោះដាន វណ្ណា ដេកពាក់មាសនាងខ្ញុំពុំព្រមសង នៅពេលនាងខ្ញុំទៅទារ ថាចាំលក់ដីបានសិន ដល់ពេលលក់ដីបានហើយក៏ពុំព្រមសងទៀត ហើយឈ្មោះ ដាន វណ្ណា ប្រាប់ថាកុំអាលយកអី ខ្ញុំទុកលុយទិញផ្ទះសិន ។ នាងខ្ញុំសុំអង្វរពរតុលាការកំពូល ជួយរកយុត្តិធម៌ដោយអនុគ្រោះ ។

- បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះ ដាន វណ្ណា នៅពេលជំនុំជំរះថា គាត់និយាយខុសពីការពិតទាំងស្រុង គាត់ថាប្តីនាងខ្ញុំដេកពាក់មាសគាត់ ប៉ុន្តែខ្ញុំពុំបានដឹងពីការនោះទេ ។ គាត់ទាមទារហួសពីសមត្ថភាពរបស់នាងខ្ញុំ ប្តីនាងខ្ញុំដេកពាក់មាសគាត់តែមួយដងឡើងប៉ុណ្ណោះ តែគាត់ទារដល់ទៅ ៦ដងឡើង ។ សូមតុលាការជួយរកយុត្តិធម៌ ។

- បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក ជា តារា ជាមេធាវីការពារអោយជនជាប់ចោទឈ្មោះ សោម កុលធីតា នៅពេលជំនុំជំរះថា :

យោងតាមមាត្រា២០៧ និង២០៨ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ យោងតាមរបាយការណ៍របស់ចៅក្រមរបាយការណ៍ និងយោងតាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូល ខ្ញុំសូមឯកភាពទាំងស្រុង ហើយសុំអោយបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ ហើយសូមតុលាការកំពូលចង្អុលបង្ហាញចំណុចខ្វះខាតរបស់សាលាឧទ្ធរណ៍ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទ របស់ដើមបណ្តឹងរដ្ឋប្បវេណីនិងសេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ៤៣៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ របស់អ្នកស្រី សោម កុលធីតា និងបណ្តឹងសាទុក្ខលេខ ៤៥៦ ចុះថ្ងៃទី៨ ខែ ធ្នូ ឆ្នាំ ១៩៩៧ របស់អ្នកស្រី ផាន ន៉ណ្ណា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងលក្ខណភាពរបស់សាលាជំរះក្តី ។
- យល់ឃើញថា សាលាឧទ្ធរណ៍មានការភន្តច្រឡំក្នុងការពិចារណាអំពីសាលក្រមព្រហ្មទណ្ឌលេខ ០៣ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ ១៩៩៧ របស់តុលាការក្រុងភ្នំពេញ តាមពិតក្នុងសំណុំរឿងពុំមានសាលក្រមនេះឡើយ ឯលេខ ០៣ ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៩៧ ជាលេខនិងកាលបរិច្ឆេទ នៃសំណុំរឿងរបស់សាលាឧទ្ធរណ៍ទេ ប៉ុន្តែកំហុសនេះជាកំហុសផ្នែកលំអារៈប៉ុណ្ណោះ ។
- យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា មូលហេតុដែលនាំអោយមានបទល្មើសនេះកើតឡើងនោះ គឺបណ្តាលមកពីការទិងទុះរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនព្រមសងបំណុលទៅអោយជនជាប់ចោទ ហើយក្នុងពេលកើតហេតុនោះជនជាប់ចោទក៏បានសុំសមត្ថកិច្ចអោយជួយដោះស្រាយដែរ ម្យ៉ាងទៀតជនជាប់ចោទទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង ហើយជាស្ត្រីភេទ មេម៉ាយមានកូនច្រើននាក់ក្នុងបន្ទុក ដែលត្រូវទទួលបានការសំរាលទោសតាមមាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។
- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២០៨ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៩៧ របស់សាលាឧទ្ធរណ៍ ដែលបានលើកមកនេះ មានលក្ខណៈត្រឹមត្រូវទាំងទំរង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី

១ - ទទួលបណ្តឹងសាទុក្ខលេខ ៤៣៧ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ របស់អ្នកស្រី សោម កុលធីតា និង បណ្តឹងសាទុក្ខលេខ ៤៥៦ ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ១៩៩៧ របស់អ្នកស្រី ផាន ន៉ណ្ណា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - ឥទ្ធិពលសាលដីកាព្រហ្មទណ្ឌលេខ ៦០៨ ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ១៩៥៧ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣ - សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៥៨ ។